# ភាពសំខាន់ចំពោះការយល់ដឹងរឿងភាសា

ភាសានិយាយ មានការអភិវឌ្ឍន៍ឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ ហើយការអភិវឌ្ឍន៍នេះ ជួនកាលមានភាពជាវិជ្ជមាន តែជួនកាលមានភាពជាអវិជ្ជមាន។ ភាសាគឺជាឧបករណ៍ចាំបាច់មួយក្នុងការកំណត់ជោគវាសនារបស់មនុស្សយើងម្នាក់ៗ។ ដូច្នេះ ការយល់ឲ្យបានច្បាស់និងអាចយកភាសាទៅប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព គួរតែស្វែងយល់លក្ខណៈយល់ខុសនៃភាសាខ្មែរខ្លះ ដូចដែលនឹងលើកមកអធិប្បាយដូចតទៅនេះ

## កម្ម

**កម្ម** ជាពាក្យសំខាន់មួយដែលខ្មែរយើងស្គាល់និងប្រើប្រាស់ច្រើនជាងគេ។ ខ្មែរយើងភាគច្រើនយល់ថាកម្មជាគំនាបមួយធ្វើឲ្យខ្មែរជួបប្រទះតែសេចក្ដីទុក្ខសោក សង្គ្រាមក្នុងស្រុក ជាពិសេសពួកគេម្នាក់ៗ ពេលធ្វើអ្វីមិនបានសំរេចឬជួបប្រទះឧបទ្ទវហេតុផ្សេងៗ ច្រើនស្ដីបន្ទោសទៅលើកម្មរបស់ខ្លួន។ ការយល់ដូច្នេះ ជាការសំដៅទៅលើពាក្យកម្មថាជារបស់ *អាក្រក់ មិនប្រសើរ មិនមានសុពលភាព និងមិនគួរជាទីចង់បាន*។

តាមពិតនេះជាការយល់ខុសមួយធំណាស់ ហើយការយល់ខុសចំពោះកម្មនេះ បានគ្របសង្កត់ចិត្តវិញ្ញាណសង្គមខ្មែរអស់រយៈពេលរាប់សតវត្សន៍មកហើយ។ ជួនកាលពួកបរទេសច្បៀតប្រើពាក្យនេះដើម្បីគ្របសង្កត់កំឡាំងសតិបញ្ញានិងការតស៊ូរបស់ខ្មែរយើងមិនឲ្យងើបមុខរួច ។

ការយល់ថាកម្មជារបស់អាក្រក់ ហើយមានលក្ខណៈអវិជ្ជមានជាការខុសទាំងស្រុងទៅនឹងអត្ថន័យពាក្យដើមរបស់កម្ម និងតួនាទីរបស់ពាក្យនេះ ។

**កម្ម** ជាភាសាបាលី ឬ **កម៌** ជាភាសាសំស្ក្រឹត ដែលមានន័យជាភាសាខ្មែរថា អំពើ ឬការប្រព្រឹត្ត។ កម្មជាពាក្យកណ្ដាល។ មិនបានសំដៅថាជាល្អឬអាក្រក់ឡើយ។

ពេលយើងប្រើពាក្យថា **កុសលកម្ម**[1] សំដៅទៅលើកម្មណាដែលល្អ នាំមកនូវសេចក្តីសុខ បើយើងនិយាយថា**អកុសលកម្ម** សំដៅទៅលើកម្មណាដែលអាក្រក់ នាំមកនូវសេចក្តីទុក្ខ។

*តើស្រុកខ្មែរយើងជួបប្រទះតែសង្គ្រាម ព្រោះបណ្តាលមកពីកម្មមែនឬទេ?*

- ការនិយាយដូច្នោះគឺមិនត្រឹមត្រូវទេ ព្រោះកម្មមិនបានធ្វើឲ្យកើតសង្គ្រាម ឬសន្តិភាពដែរ លុះត្រាណាតែយើងប្រព្រឹត្តអំពើជាកុសលកម្ម ឬ អកុសលកម្ម ទើបផលឬវិបាកកើតឡើង។ ដូច្នេះសំណួរឬចំងល់ដែលត្រឹមត្រូវ យើងគួរសួរខ្លួនឯងថា តើស្រុកខ្មែរយើងជួបប្រទះតែសង្គ្រាម ព្រោះបណ្តាលមកពីយើងប្រព្រឹត្តអកុសលកម្មច្រើនមែនឬទេ?

ពិតណាស់ការនិយាយដូច្នោះ ហាក់ដូចជាដាក់ទោសខ្លួនឯង ប៉ុន្តែយើងត្រូវដឹងថា មកពីខ្មែរយើងនិយមជឿទៅលើព្រហ្មលិខិតជាងកម្មលិខិត ទើបនាំមកនូវវាសនាអាក្រក់ជាបន្តបន្ទាប់។ កត្តាដែលខ្មែរយើងរាល់រូបមិនបានព្យាយាមស្វះស្វែងសិក្សាស្រាវជ្រាវអភិវឌ្ឍន៍ចំណេះដឹងនិងសតិបញ្ញា បញ្ចៀសខ្លួនឲ្យផុតពីគ្រោះអវិជ្ជា នោះឯងជាការប្រចាំងនឹងច្បាប់នៃទ្រឹស្តីកម្មផល ។

តើកម្ម និង កម្ពុជាដូចគ្នាឬខុសគ្នាយ៉ាងណា?

- មានខ្មែរយើងមួយភាគខ្លះដែលគិតថាកម្ពុជាជួបភ័យវិបត្តិ ពីព្រោះតែកម្មរបស់ខ្លួនហើយរហូតដល់បន្ទោសថាមកពីយើងមានឈ្មោះប្រទេសថា **កម្ពុជា** គឺមានកម្មរហូត។ តាមសេចក្តីពិតកម្ពុជាមិនមែនកម្មនោះទេ កម្ពុជាគឺទឹកដីឬប្រទេសមួយដែលកើតមកពីឥសី **ឈ្មោះកម្ពុ** រៀបអភិសេកជាមួយ **នាងមេរា** ទើបកើត

---

*១. សំដៅទៅលើកុសលកម្ម១០ មានដូចជា : ~ កាយកម្ម៣(១.សំឡាប់សត្វ, ២.លួចទ្រព្យអ្នកដទៃ, ៣.ប្រព្រឹត្តខុសផ្លូវ ភេទ), វចីកម្ម៤(៤.និយាយកុហក, ៥.និយាយញុះញង់បំបែកបំបាក់គេ, ៦.និយាយពាក្យអសុរស, ៧.និយាយពាក្យឥតប្រយោជន៍) និងមនោកម្ម៣(៨.គិតតែសំឡឹងចង់បានទ្រព្យអ្នកដទៃ, ៩.គិតតែព្យាបាទគេ, ១០.មានសេចក្តីយល់ឃើញខុស)។*

ជាកម្ពុជាឡើង។ ឬម្យ៉ាងវិញទៀតអាចមានន័យថា ទឹកដីដែលសំបូរទៅដោយ មាស និង ពេជ្រ ។

*កម្ម តាមន័យលោកុត្តរធម៌*

ន័យពិតដែលបញ្ជាក់នូវវាលវដ្តសង្សារ ការកើតចាស់ឈឺស្លាប់ គឺបណ្តាលមកពី **កិលេស កម្ម និងវិបាក**។ កាលណាយើងមានកិលេសបណ្តាលឲ្យយើងធ្វើនូវកម្ម កាលណាយើងមានកម្ម ធ្វើឲ្យយើងទទួលនូវផលគឺវិបាក។ ដូច្នេះព្រះអរហន្តទាំងឡាយបានប្រើប្រាស់នូវកម្មជាកុសលដើម្បីជាវិធីកំចាត់នូវកិលេសទាំងពួង។ ពេលកិលេសទាំងអស់ត្រូវបានដួសឲ្យជ្រះស្រឡះហើយ វាលវដ្តសង្សារក៏ត្រូវបានបញ្ចប់ ព្រះនិព្វានក៏ត្រូវបានសំរេច ។

## វេទនា

ពុទ្ធសាសនិកជនខ្មែរយើង ពេលនិយាយឬនឹកដល់វេទនា តែងតែគិតថាជាសេចក្តីទុក្ខ ដែលនេះជាអភិវឌ្ឍន៍ផ្តត់គំនិតទៅរកភាពខុស ប្រាសចាកការយល់តាមសភាវពិតរបស់វា។ តាមពិតវេទនាមានន័យដោយសព្វថា *ការសោយនូវអារម្មណ៍ដែលមកប៉ះទង្គិចនឹងចិត្តរបស់យើង*។ ជាក់ស្តែងពេលណាមានអារម្មណ៍មិនសប្បាយចិត្ត ទុក្ខក្រៀមក្រំ អន្ទះអន្ទែង មួរម៉ៅ សោកសង្រេង **ហៅថាទុក្ខវេទនារម្មណ៍**។ តែពេលណាយើងមានអារម្មណ៍សប្បាយ ធូរស្រាលក្នុងចិត្ត ពេញចិត្ត មានបីតិសោមនស្សរីករាយ ហៅថា**សុខវេទនារម្មណ៍**។ តែជួនកាល យើងហាក់បីដូចជាមិនកើតទុក្ខហើយក៏មិនសប្បាយចិត្តដែរ មានអារម្មណ៍ជាធម្មតា។ តាមសភាវៈពិតនៃធម្មជាតិ នេះហៅថា **ឧបេក្ខារម្មណ៍**(*អទុក្ខមសុខរម្មណៈ*)។

ដើម្បីឲ្យជាប្រយោជន៍ច្រើន និងអភិវឌ្ឍន៍កំរិតសតិបញ្ញាឲ្យកាន់តែខ្ពស់ឡើយ ពុទ្ធសាសនិកជនខ្មែរ ត្រូវតែយល់នូវនិយមន័យពិតប្រាកដរបស់វេទនានេះឲ្យបានច្បាស់លាស់ ដូចជាពាក្យថាកម្មនោះផងដែរ។